# សេចក្តីសង្ខេបអំពី ការប្រព្រឹត្តខុសច្បាប់តម្រូវបញ្ឈប់រៀនជាបណ្តោះអាសន្ន ឬឲ្យបណ្តេញចេញពីសាលា

ការបណ្តេញចេញគឺ " ត្រូវដកសិស្សជាបន្ទាន់ចេញពីការគ្រប់គ្រង និងការត្រួតត្រា, ឬការគ្រប់គ្រងទូទៅពីបុគ្គលិកសាលារៀន។" ការបណ្តេញចេញ សិស្សមិនអាចចូលរួមជាមួយកម្មវិធីរបស់ក្រសួងអប់រំប្រចាំក្រុង ឬចូលរួមជាមួយសកម្មភាពអ្វីមួយបាន, រួមទឹងកម្មវិធីសិក្សាដោយម្ចាស់ការ។ ច្បាប់គ្រប់គ្រងលេខ ៦២៩៥ ជាទម្រង់ច្បាប់ដ៏ពេញលិញរបស់ក្រសួងអប់រំស្តីអំពី ការបណ្តេញសិស្សចេញពីសាលារៀន និងច្បាប់គ្រប់គ្រងលេខ៦២៩០ជាទម្រង់ច្បាប់បណ្តេញសិស្សចេញពីសាលារៀន។ ច្បាប់ទាំងពីរនេះអាចស្នើសុំពីសាលារៀនរបស់កូនលោកអ្នក ឬចម្លងចេញពីប្រព័ន website: www.sandi.net/policy.

សិស្សមិនអាចទទួលការបញ្ឈប់រៀនជាបណ្តោះអាសន្ន ឬបណ្តេញចេញពីសាលារៀនលើកលែងតែអគ្គស្នងការអប់រំ ឬចាងហ្វាងសាលារៀនសម្រេចថា សិស្សបានប្រព្រឹត្តល្មើសនឹងច្បាប់ណាមួយ ឬលើសពីនេះដែលបណ្តាលអោយបញ្ឈប់ការមករៀនជាបណ្តោះអាសន្ន និង/ឬបណ្តេញចេញពីសាលារៀន:

## សង្ខេប

- ❖ សិស្សមិនអាចទទួលការបញ្ឈប់រៀនជាបណ្តោះអាសន្ន ឬបណ្តេញចេញពីសាលារៀនលើកលែងតែអគ្គស្នងការអប់រំ ឬចាងហ្វាងសាលារៀនសម្រេចថា សិស្សបានប្រព្រឹត្តល្មើសនឹងច្បាប់ណាមួយ ឬលើសពីនេះដែលបណ្តាលអោយបញ្ឈប់ការមករៀនជាបណ្តោះអាសន្ន ឬបណ្តេញចេញពីសាលារៀនក្រោមទម្រង់ការគ្រប់គ្រងច្បាប់លេខ ៦២៩៥ ឬ៦២៩០។
- ❖ សិស្សប្រព្រឹត្តល្មើសនឹងច្បាប់វិន័យពិតប្រាកដណាមួយនៅតាមសាលារៀន ឬសកម្មភាពអ្វីមួយក្រៅលើទីធ្លាសាលារៀនតម្រូវជាបន្ទាន់ឲ្យឈប់រៀនជាបណ្តោះអាសន្ន ឬបណ្តេញឲ្យចេញពីសាលារៀនក្រោមច្បាប់ "ចំបាច់មិនឲ្យមានអាវុធនៅតាមសាលារៀន។"
- ❖ មានតែគណៈកម្មការក្រសួងអប់រំអាចបណ្តេញសិស្សបាន។

- **ការវាយតប់/វាយតប់យ៉ាងធ្ងន់ធ្ងរ** - រួមទឹងការប៉ុនប៉ង ឬគំរាមកំហែងធ្វើឲ្យមានរបួសលើរាងកាយ ឬគំរាមកំហែងឬវាយតប់គ្នាបណ្តាល ឲ្យមានមិនមានរបួស; ប្រើកម្លាំង ឬធ្វើឲ្យបុគ្គលណាម្នាក់របួស, លើកលែងតែការពារខ្លួន; ប្រើកម្លាំង ឬធ្វើឲ្យបុគ្គលណាម្នាក់របួសធ្ងន់ធ្ងរ លើកលែងតែការពារខ្លួន; ការវាយតប់ ឬវាយតប់ធ្ងន់ធ្ងរទៅលើបុគ្គលិកសាលារៀន, ការប្រព្រឹត្ត ឬប៉ុនប៉ងវាយតប់ និងគ្រោះថ្នាក់លើផ្លូវភេទ។
- **គ្រឿងអាវុធ** - រួមទឹងមានអាវុធ, លក់ ឬផ្តល់អាវុធ, កាំបិតគ្រប់ប្រភេទ, គ្រឿងផ្ទុះ, ឬរបស់ទូទៅដែលធ្វើឲ្យមានគ្រោះថ្នាក់។
- **ប្លន់ ឬគំរាមកំហែង** - រួមទឹងការប៉ុនប៉ងប្លន់ ឬគំរាមកំហែង។
- **ការធ្វើឲ្យខូចខាតទ្រព្យសម្បត្តិសាលារៀន ឬទ្រព្យសម្បត្តិឯកជន** - ប៉ុនប៉ង ឬបណ្តលអោយខូចខាត។
- **ការលួចទ្រព្យសម្បត្តិ** - ប៉ុនប៉ងលួច, បានលួច, ឬទទួលរបស់របរលួច។
- **ថ្នាំជក់** - មានថ្នាំជក់, ផ្តល់ថ្នាំជក់, ចាត់ចែង ឬលក់ថ្នាំជក់។
- **ថ្នាំញៀន, គ្រឿងស្រវឹង ឬគ្រឿងមានជាតិពុលណាមួយ** - រួមទឹងមាន, ប្រើប្រាស់, ចែកចាយ, លក់, របស់ខុសច្បាប់ទាំងនេះ។ បន្ថែម បើគេចាប់បានសិស្សមានកញ្ឆាតិចជាងមួយអោនចំនួនមួយដង ឬពីរដង សិស្សទឹងទទួលការបញ្ឈប់រៀនពីសាលារៀនជាបណ្តោះអាសន្ន; បើសិស្សប្រើ ឬមានជាតិគ្រឿងខុសច្បាប់ទាំងនេះ សិស្សទឹងទទួលការបណ្តេញចេញពីសាលារៀនក្រោមច្បាប់ល្មើសកំរិតទី បី។
- **របស់ដែលទាក់ទងនឹងគ្រឿងស្រវឹង/ត្រួតត្រាលើគ្រឿងទាំងនេះ** - បញ្ជូន, ចែកចាយ និង/ឬលក់របស់ដែលទាក់ទងនឹងគ្រឿងញៀន ឬគ្រឿងស្រវឹង។
- **គ្រឿងញៀន Paraphernalia** - មានគ្រឿងញៀនខុសច្បាប់, ផ្តល់ ឬលក់គ្រឿងញៀនខុសច្បាប់។
- **ការនិយាយពាក្យមិនល្អ/ពាក្យមិនសមរម្យ/ពាក្យថោកទាប** - ការប្រព្រឹត្តអំពើមិនល្អ, ទាក់ទងនឹងទម្លាប់ប្រើពាក្យមិនសមរម្យ/ពាក្យថោកទាប។
- **ការរំខាន, រឹងទទឹង** - ការរំខានដល់សកម្មភាពសិក្សានៅតាមសាលារៀន ឬមានបំណងបំពានទៅលើបុគ្គលិកសាលារៀន។
- **ការយាយីតាមផ្លូវភេទ (ថ្នាក់ទី ៤ ដល់ ១២)** - សំរាប់តែសិស្សថ្នាក់ទី ៤-១២ អាចបណ្តេញ ចេញពីសាលារៀន ពេលមានរឿងកើតឡើង។
- **ការស្អប់អំពើឧក្រិដ្ឋកម្ម (ថ្នាក់ទី ៤-១២)** - បណ្តាលឲ្យមាន, គំរាមកំហែងឲ្យមាន, ប៉ុនប៉ងឲ្យមានឧក្រិដ្ឋកម្ម, ឬចូលរួមប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម។ ចំពោះតែសិស្សថ្នាក់ទី ៤-១២ ត្រូវបណ្តេញចេញពីសាលារៀន ពេលមានបញ្ហានេះកើតមានឡើង។
- **គម្រាមកំហែង និងបំភ័យ** - យាយី, បំភ័យ, ឬគំរាមកំហែងដល់សិស្សដែលធ្វើជាសាក្សីរឿងរ៉ាវអ្វីមួយ ឬសងសឹកនឹងសិស្សដែលធ្វើជាសាក្សី។
- **ការយាយី (ថ្នាក់ទី ៤-១២)** - យាយី, បំភ័យ, ឬគំរាមកំហែងដល់សិស្ស ឬក្រុមសិស្ស ឬបុគ្គលិកសាលារៀនទូវព្រឹត្តការដូចជា: (១) រំខានដល់កិច្ចការក្នុងថ្នាក់, ឬ(២) បង្កើតឲ្យមានរឿងរ៉ាវ, ឬ(៣) បង្កើតការបំភ័យ ឬរំខានដល់បរិយាកាសសិក្សា។ ចំពោះតែសិស្សថ្នាក់ទី ៤-១២ ត្រូវតែបណ្តេញចេញពីសាលារៀន ពេលមានបញ្ហានេះកើតមានឡើង។
- **គ្រឿងអាវុធក្លែងក្លាយ** - មានអាវុធក្លែងក្លាយ។
- **ការគម្រាមកំហែងធ្វើភេរវកម្មដល់បុគ្គលិកការងារ ឬទ្រព្យសម្បត្តិសាលារៀន** - សរសេរជាលិខិត ឬនិយាយដែលមានបំណងគម្រាមកំហែងប្រព្រឹត្តអំពើឧក្រិដ្ឋកម្មដែលធ្វើឲ្យស្លាប់ ឬគ្រោះថ្នាក់របួសដល់រាងកាយខ្លាំង និងបំផ្លាញដល់ទ្រព្យសម្បត្តិ។
- **ថ្នាំពេទ្យចេញពីលោកវេជ្ជបណ្ឌិត**- ចែកចាយ, លក់, ឬប៉ុនប៉ងលក់ថ្នាំ Soma ។

-បន្ត-

មិនមានសិស្សណាម្នាក់ទទួលបញ្ឈប់រៀនជាបណ្តោះអាសន្ន ឬទទួលការបណ្តេញចេញពីសាលារៀនទូវអំពើសកម្មភាពអ្វីមួយ លើកលែងតែអំពើនោះមានការទាក់ទងនឹងកម្មវិធីសាលារៀន ឬការមករៀន។ សិស្សអាចទទួលការបញ្ឈប់រៀនជាបណ្តោះអាសន្ន ឬទទួលការបណ្តេញចេញពីសាលារៀនគ្រប់ពេលវេលា នូវអំពើខាងលើនេះដែលបានប្រព្រឹត្ត ប៉ុន្តែមិនកំណត់ទៅលើ (a) ពេលនៅលើទីធ្លាសាលារៀន (b) ពេលធ្វើដំណើរទៅ និងមកពីសាលារៀន (c) ពេលញ៉ាំអាហារថ្ងៃត្រង់, ឬនៅក្នុងសាលារៀន ឬក្រៅសាលារៀន (d) ពេលទៅ និងមកពីសាលារៀន នៅពេលសាលារៀនធ្វើពិធីអ្វីមួយ។ បើសិស្សទទួលការចាប់ចងពីក្រសួងប៉ូលីស សិស្សនឹងទទួលការបញ្ឈប់រៀនជាបណ្តោះអាសន្ន នៅពេលនោះតែម្តង ឬនៅពេលត្រឡប់មកដល់សាលារៀនវិញ។

**ការប្រព្រឹត្តល្មើសច្បាប់ទូវអំពើប្រាកដណាមួយនៅតាមសាលារៀន ឬសកម្មភាពអ្វីមួយនៅតាមទីធ្លាសាលារៀនតម្រូវអោយបញ្ឈប់រៀនជាបណ្តោះអាសន្ន ឬទទួលការបណ្តេញចេញពីសាលារៀនជាបន្ទាន់ក្រោម " ច្បាប់បំបាត់មិនអោយមានគ្រឿងអាវុធនៅតាមសាលារៀន "។ ពត៌មានក្បោះក្បាយ ចូរពិនិត្យមើលច្បាប់គ្រប់គ្រងសាលារៀន SDCS លេខ ៦២៩៥។**

ការប្រព្រឹត្តល្មើសនឹងច្បាប់បំបាត់មិនអោយមានគ្រឿងអាវុធនៅតាមសាលារៀនតម្រូវអោយបណ្តេញចេញពីសាលារៀន។ ការប្រព្រឹត្តល្មើសគឺមានដូចជា:

<u>សិស្សទាំងអស់ដែលប្រព្រឹត្តល្មើសច្បាប់</u>

- **មាន, លក់ ឬចែកចាយគ្រឿងកាំភ្លើងទូទៅ** (បញ្ជាក់ក្រោមច្បាប់សហរដ្ឋអាមេរិក ១៨រដ្ឋ មាត្រាលេខ ៩២១)
- **គ្រវីកាំបិតដាក់បុគ្គលណាមួយ** ( "កាំបិត" មានន័យថា កាំបិតគ្រប់ធុន, កាំបិតកែ, ឬអាវុធផ្សេងៗ, របស់ដែលមុខធ្វើអោយមានគ្រោះថ្នាក់, អាវុធដែលមានទំហំ៣អ៊ីនកន្លះ, កំបិតបត់, កាំបិតកោរ)។
- **ការលក់របស់ខុសច្បាប់** (បញ្ជីនៅក្នុងមច្បាប់សុខភាព និងសន្តិសុខលេ ១១០៥៣)
- **ការវាយតប់ និងគ្រោះថ្នាក់លើផ្លូវភេទ**
- **មានគ្រឿងផ្ទុះ**

<u>សិស្សសាលាមធ្យមសិក្សា</u>

- **គ្រឿងអាវុធ, ការប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម និងវាយតប់គ្នាមិនឈប់ឈរ.** សិស្សអនុវិទ្យាល័យ, វិទ្យាល័យ និងសិស្សមធ្យមសិក្សាដែលមានការទាក់ទងនឹងរឿងរ៉ាវវាយតប់គ្នាដែលធ្វើអោយមានរបួសចំនួនបីដង ឬលើសពីនេះ ឬប្រព្រឹត្តខុសក្នុងរយៈពេលមួយឆ្នាំនឹងទទួលការបណ្តេញចេញពីសាលារៀនជាបណ្តោះអាសន្ន ឬបណ្តេញចេញពីសាលារៀន។ សិស្សដែលមានកាំភ្លើង, កាំបិត, គ្រឿងផ្ទុះ, ឬរបស់ដែលធ្វើអោយមានគ្រោះថ្នាក់នៅក្នុងសាលារៀននឹងតម្រូវបញ្ឈប់រៀនជាបណ្តោះអាសន្ន ឬបណ្តេញចេញពីសាលារៀន។ គោលបំណងនៃច្បាប់បំបាត់មិនអោយសិស្សមានគ្រឿងអាវុធនៅតាមសាលារៀនគឺកំចាត់មិនអោយសិស្សប្រើអាវុធ, ប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម និងវាយតបគ្នានៅតាមសាលារៀន។ បើសិស្សប្រព្រឹត្តល្មើសនឹងច្បាប់មានគ្រឿងអាវុធ គេនឹងផ្តល់ពត៌មានដល់ក្រសួងប៉ូលីសប្រចាំសាលារៀន សាន់ឌីអេហ្គោ និងក្រសួងប៉ូលីសប្រចាំក្រុង សាន់ឌីអេហ្គោ ជាមិនខាន។
- **គ្រឿងស្រវឹង, ថ្នាំជក់, និងគ្រឿងញៀនផ្សេង.** ច្បាប់ក្រសួងអប់រំប្រចាំក្រុងនឹងធ្វើការបណ្តេញចេញពីសាលារៀនក្នុងករណីតច្បាប់ទីមួយ បើបុគ្គលិកពិនិត្យទៅឃើញថាសិស្សចែកចាយ, លក់ ឬមានគ្រឿងខុសច្បាប់ច្រើនជាងការប្រើហួសកំណត់, ការប្រើ ឬមានគ្រឿងញៀនខុសច្បាប់ចាត់ទុកជាករណីតច្បាប់ទី បី, លើកលែងតែការប្រើថ្នាំជក់; ការប្រព្រឹត្តល្មើសច្បាប់ទាក់ទងនឹង ថ្នាំជក់ករណីតទី បួន សិស្សនឹងទទួលការបញ្ឈប់រៀនពីសាលារៀនជាបណ្តោះអាសន្នចំនួន ប្រាំ (៥) ថ្ងៃ ជាមួយការស្នើសុំបណ្តេញចេញពីសាលារៀន។
- **ការប្លន់ ឬការគំរាមកំហែង**
- **បណ្តាលអោយគ្រោះថ្នាក់ធ្ងន់ធ្ងរ**
- **ការវាយតប់ និងធ្វើអោយមានគ្រោះថ្នាក់ដល់បុគ្គលិកការងារ**
- **មាន, បានលក់ ឬចែកចាយគ្រឿងអាវុធជ័រ/អាវុធក្លែងក្លាយ**

**មានតែគណៈកម្មការក្រសួងអប់រំអាចបណ្តេញសិស្សឲ្យចេញពីសាលារៀនបាន។** ការសម្រេចចិត្តរបស់គណៈកម្មការក្រសួងអប់រំបណ្តេញសិស្សចេញពីសាលារៀន យោងទៅតាមភស្តុតាងដែលគេរកឃើញទាក់ទងនឹងការប្រព្រឹត្តខុសច្បាប់បង្ហាញនៅពេលប្រជុំតវ៉ា មុនគណៈកម្មការសើរើការបណ្តេញសិស្សចេញ។

បោះពុម្ពដែលមានការគាំទ្រពីសមាគម Annie E. Casey

ទាក់ទងពត៌មានៈ ការិយាល័យចំណាត់ថ្នាក់ និងគាំ (៦១៩) ៧២៥-៥៦៦០
ការតម្រូវតាមសាធារណៈ (៦១៩) ៧២៥-៥៥៧៨ www.sandi.net

ការបំរើសិស្សជាង ១៣៦០០០នាក់, សាលារៀនប្រចាំទីក្រុង សាន់ឌីអេហ្គោ គឺជាសាលារៀនប្រចាំក្រុងធំទី ពីរ ក្នុងចំណោមសាលារៀនទាំងអស់នៅក្នុងរដ្ឋ កាលីហ្វ័រញ៉ា ដែលមានមណ្ឌលចំនួនជាង ២០២ ព្រមទាំងបុគ្គលិកចំនួន ១៤៥០០នាក់ធ្វើការពេញម៉ោង (តំណាងបុគ្គលិកជាង ១៥៨០០នាក់)។ SDCS ពង្រឹងការអប់រំសិស្សតាមជំនាញគោលការអប់រំផ្នែក រៀនអាន, សរសេរ និងគណិតសាស្ត្រសំរាប់សិស្សបុរេដ្ឋានដល់ថ្នាក់ទី ១២។ ក្រសួងអប់រំប្រចាំក្រុងផ្តាច់ញ៉ាគាំទ្រសាលារៀន និងបង្កើនបរិយាកាសដល់សិស្សសិក្សានៅតាមបន្ទប់រៀនដោយកែប្រែមណ្ឌលសិក្សា និងទទួលប្រភពពត៌មានទូទៅ និងតាមមាតាបិតាសិស្ស, ការទាក់ទងពីលោកគ្រូ-អ្នកគ្រូ និងសហគមន៍តាមរបៀបអប់រំ។

" បេសកកម្មរបស់ក្រសួងអប់រំប្រចាំទីក្រុង សាន់ឌីអេហ្គោ គឺពង្រឹងការសិក្សាសិស្សឲ្យបានសម្រេច ដោយគាំទ្រការបង្រៀនរបស់លោកគ្រូ-អ្នកគ្រូ ព្រមទាំងការសិក្សារបស់សិស្សនៅតាមបន្ទប់រៀន។ "

Summary of Offenses Leading to Suspension or Expulsion. Cambodian.